របាយការណ៍នៃការរីកចម្រើនរបស់សាលា ស្តីពីការអប់រំ និងសមធម៌ សម្រាប់ឆ្នាំ ២០២១-២០២២

# សំណួរដែលគេ

# ខ្វស្សាហ៍សួរ (FAQs)

# សំណួរដែលគេឧស្សាហ៍សួរ

**តើរបាយការណ៍នៃការរីកចម្រើនរបស់សាលាស្តីពីការអប់រំ និងសមធម៌ (SPREE) ជាអ្វី?**

SPREE គឺជារបាយការណ៍ស្តីពីលទ្ធផលដែលសិស្សរៀនបាន និងការរីកចម្រើននៃសាលារបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា តាមពេលវេលា។ របាយការណ៍នេះផ្តល់ព័ត៌មានថាតើសាលា - និងក្រុមសិស្សនៅក្នុងសាលា - ធ្វើបានកម្រិតណាក្នុងការប្រៀបធៀបទៅនឹង [គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឱ្យសិស្សមានជោគជ័យ (Goals and Guardrails)]() របស់ក្រុមប្រឹក្សាអប់រំ។

របាយការណ៍នេះក៏ប្រៀបធៀបលទ្ធផលដែលសិស្សរៀនបានរបស់សាលាទៅនឹងគោលដៅដែលរដ្ឋបានកំណត់សម្រាប់លទ្ធផលដែលសិស្សរៀនបានរបស់សាលាផងដែរ។

**តើ SPREE ខុសគ្នាយ៉ាងណាសម្រាប់ ឆ្នាំសិក្សា ២០២១-២០២២?**

សម្រាប់ឆ្នាំសិក្សា ២០២១-២០២២ ក្រសួងអប់រំបង្កើតរបាយការណ៍ "SPREE"។ ដោយសារតែនេះគឺជាការចេញផ្សាយដំបូងនៃរបាយការណ៍ស្តង់ដារ ហើយដោយសារតែវាតំណាងឱ្យឆ្នាំដំបូងដែលយើងមានទិន្នន័យទូលំទូលាយ ចាប់តាំងពីមានជំងឺរាតត្បាត COVID-19 វារួមបញ្ចូលទិន្នន័យនៃលទ្ធផលដែលសិស្សរៀនបានរបស់សាលា។ នៅឆ្នាំក្រោយៗ SPREE ក៏នឹងវាស់វែងការផ្លាស់ប្តូរលទ្ធផលដែលសិស្សរៀនបានពីឆ្នាំមុនផងដែរ។ របាយការណ៍ SPREE ឆ្នាំ ២០២១-២០២២ មើលទៅខុសគ្នាពី "SPREE Lite" ដែលក្រសួងអប់រំបានបង្កើតក្នុងឆ្នាំ ២០២០-២០២១ ពីព្រោះគ្មានការវាយតម្លៃជាច្រើនពីមុនមក ដោយសារៈ

- ការផ្លាស់ប្តូរទូទាំងរដ្ឋ ចំពោះតម្រូវការចូលរួមក្នុងការវាយតម្លៃរបស់រដ្ឋ ដោយសារការរាតត្បាតជាសាកលនៃជំងឺ COVID-19
- ទិន្នន័យដែលមិនទាន់ប្រមូលបានសម្រាប់សាលារបស់ក្រសួងអប់រំ ឬសាលាឆាធ័រ (ឧ. ការចូលរួមក្នុងសកម្មភាពកម្មវិធីសិក្សារួម)
- ទិន្នន័យដែលសាលាឆាធ័រមិនធ្លាប់បានស្នើសុំឲ្យប្រមូល ឬរាយការណ៍ពីមុនមក (ឧ. ភាគរយនៃសិស្សដែលចូលរួមក្នុង សិល្បៈគំនូរ ឬសិល្បៈសម្តែង)

ទោះបីជា SPREE ឆ្នាំនេះ មានភាពពេញលេញជាង SPREE Lite ក៏ដោយ ក៏វានៅតែមើលទៅខុសគ្នាពីរបៀបដែលវានឹងត្រូវបានបង្ហាញនាពេលអនាគត។ SPREE នៅឆ្នាំនេះនឹងខុសពី SPREE ពេញលេញដូចតទៅៈ

- គ្មានលទ្ធផលដែលសិស្សរៀនបានពីឆ្នាំមុន ឬការប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំ ហើយដូច្នេះរបាយការណ៍នឹងមិនរួមបញ្ចូលព័ត៌មានថាតើសាលាធ្វើបានប្រសើរជាងមុន ឬអត់នោះទេ។
- ដោយសារកង្វះនៃការប្រៀបធៀបពីមួយឆ្នាំទៅ

មួយឆ្នាំ សាលានឹងទទួលតែកម្រិតសរុបនៃ 1, 3 ឬ 5 តែប៉ុណ្ណោះ។

- របាយការណ៍ SPREE នឹងមិនរួមបញ្ចូលទិន្នន័យនៃការរីកចម្រើននៅក្នុងផ្នែកអាន និងភាសាអង់គ្លេស (ELA) គណិតវិទ្យា និងវិទ្យាសាស្ត្រ ឬការរីកចម្រើនរបស់សិស្សដែលត្រូវរៀនភាសាអង់គ្លេស ទៅកាន់ជំនាញភាសាអង់គ្លេស នោះទេ។ នេះគឺដោយសារតែរង្វាស់ទាំងនេះរួមបញ្ចូលពីរបៀបដែលសិស្សធ្វើបានក្នុងការវាយតម្លៃរបស់រដ្ឋ ក្នុងអំឡុងឆ្នាំសិក្សា ២០២០-២០២១ នៅពេលដែលសិស្សមួយចំនួនតូចបានធ្វើការវាយតម្លៃរបស់រដ្ឋ។
- ដើម្បីជួយអ្នកប្រើប្រាស់ផ្តោតលើរង្វាស់សំខាន់ៗ របាយការណ៍ SPREE សម្រាប់ឆ្នាំ ២០២១-២០២២ នឹងមិនបង្ហាញទិន្នន័យសម្រាប់របៀបវាស់វែងព័ត៌មានមួយចំនួនទេ (ឧ. លទ្ធផលនៃការវាយតម្លៃគណិតវិទ្យា និងការអាន ក្នុងឆ្នាំ)។

**តើអ្វីជា គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals and Guardrails) របស់ក្រុមប្រឹក្សាភិបាល?**

ក្នុងអំឡុងឆ្នាំសិក្សា ២០២០-២០២១ ក្រុមប្រឹក្សាអប់រំបានបង្កើត គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ ប្រាំ ដែលទាក់ទងនឹងលទ្ធផលរបស់សិស្ស និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ បួន ដែលពន្យល់គ្រូសៗនូវល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ជោគជ័យរបស់សិស្ស។

គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ ប្រាំ ផ្តោតលើ៖

1) លទ្ធផលនៃការអាននៅថ្នាក់ទី៣ ដល់ ទី៨
2) លទ្ធផលនៃការអាននៅថ្នាក់ទី៣
3) លទ្ធផលនៃគណិតវិទ្យាថ្នាក់ទី៣ ដល់ ទី៨
4) លទ្ធផលនៃពិជគណិត ជិវវិទ្យា និងអក្សរសាស្ត្រនៅថ្នាក់ទី១១
5) ការរៀបចំផ្នែកឧស្សាហកម្មសម្រាប់សិស្សដែលសិក្សាផ្នែក អាជីព និងបច្ចេកទេស (CTE)

ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ បួន ផ្តោតលើ៖

1) សាលាដែលមានការស្វាគមន៍ និងគាំទ្រ
2) បទពិសោធន៍ផ្សេងៗនៅសាលាដែលមានការសិក្សាបន្ថែម និងការចូលរួមរាល់សកម្មភាព
3) ការសហការជាមួយ ឪពុកម្តាយ/សមាជិកគ្រួសារ
4) ការដោះស្រាយការប្រកាន់ពូជសាសន៍

ក្រុមប្រឹក្សាភិបាលបានកំណត់គោលដៅទុកសម្រាប់លទ្ធផលដែលចង់បានលើរង្វាស់ទាំងនេះត្រឹមឆ្នាំសិក្សា ២០២៥-២០២៦។ ក្រុមប្រឹក្សាភិបាលក៏បានកំណត់គោលដៅប្រចាំឆ្នាំសម្រាប់តាមដានការរីកចម្រើនទៅកាន់ Goals and Guardrails ក្នុងអំឡុងឆ្នាំសិក្សា ផងដែរ។

របាយការណ៍ SPREE វាស់វែងពីរបៀបដែលសាលាធ្វើបាន ប្រៀបធៀបនឹងគោលដៅប្រចាំឆ្នាំក្នុងតំបន់ទាំងនេះ សម្រាប់ឆ្នាំសិក្សាដែលបានរាយការណ៍។

**តើរបាយការណ៍ SPREE ខុសពី របាយការណ៍នៃការរីកចម្រើន (SPR) របស់សាលាយ៉ាងដូចម្តេច?**

SPR គឺជាឧបករណ៍កាលពីមុនរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្យ៉ា សម្រាប់ឱ្យដឹងពីលទ្ធផលរបស់សាលា ហើយត្រូវបានបង្កើតឡើងសម្រាប់ឆ្នាំសិក្សា ២០១២-២០១៣ ដល់ ២០១៨-២០១៩។ ជារបាយការណ៍ចុងឆ្នាំសម្រាប់ឆ្នាំ ២០១៩-២០២០ ដែលរួមបញ្ចូលរង្វាស់មួយចំនួនពី SPR ដែលបានចេញផ្សាយក្នុងឆ្នាំ ២០១៩-២០២០ ដោយសារផលប៉ះពាល់នៃការរាតត្បាតជាសាកលនៃជំងឺ COVID-19។

SPR បានវាស់វែងលទ្ធផលនៃរង្វាស់សំខាន់ៗដែលស្របតាមផែនការ 2.0 របស់អគ្គនាយកក្រសួងអប់រំមុន។ ខណៈពេលដែលរង្វាស់ជាច្រើនពីរបាយការណ៍ SPR ត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍ SPREE របាយការណ៍ SPREE វាស់វែងលទ្ធផលប្រៀបធៀបនឹងការរីកចម្រើនទៅកាន់តម្លៃគោលដៅប្រចាំឆ្នាំ ដែលស្របតាម Goals and Guardrails របស់ក្រុមប្រឹក្សាភិបាល។ របាយការណ៍ SPREE ក៏រួមបញ្ចូលកាន់តែច្បាស់លាស់នូវការវាស់វែងសមធម៌ ផងដែរ – និងរួមបញ្ចូលការបំបែកក្រុមសិស្ស – ខណៈដែល SPR រួមបញ្ចូលការវាស់វែង និងពិន្ទុដែលទាក់ទងនឹងលទ្ធផលដែលសិស្សរៀនបានទូទាំងសាលាតែប៉ុណ្ណោះ។

លើសពីនេះ របាយការណ៍ SPREE រួមបញ្ចូលនូវការវាស់វែងដែលមិនទទួលបានពិន្ទុជាច្រើនទៀត ដើម្បីផ្តល់បរិបទអំពីលទ្ធផលរបស់សិស្ស និង សាលា ខណៈពេលដែលរក្សាការផ្តោតទៅលើការវាស់វែងចំៗដែលស្របតាមគោលដៅរបស់រដ្ឋ និងតំបន់។

## តើសាលាទាំងនោះធ្វើបានដូចម្តេចបើគិតដល់គ្នាទៅវិញទៅមក នៅលើ របាយការណ៍ SPREE?

របាយការណ៍ SPREE ផ្តោតលើរបៀបដែលសាលាណាមួយកំពុងដំណើរការ ប្រៀបធៀបនឹងគោលដៅប្រចាំឆ្នាំសម្រាប់លទ្ធផលរបស់សិស្ស តាមគោលដៅរបស់រដ្ឋ និងតំបន់។ គោលដៅប្រចាំឆ្នាំទាំងនេះ ជាទូទៅកើនឡើងតាមពេលវេលា។ របាយការណ៍ SPREE ក៏ផ្តោតលើរបៀបដែលលទ្ធផលរបស់សាលាផ្លាស់ប្តូរពីឆ្នាំមុន និងរបៀបដែលសាលាកំពុងដំណើរការសម្រាប់ក្រុមសិស្សផ្សេងៗគ្នា ដែលសាលាបម្រើ។ របាយការណ៍ SPREE មិនមែនផ្តោតលើការបង្ហាញពីរបៀបដែលសាលាកំពុងដំណើរការក្នុងការប្រៀបធៀបគ្នាទៅវិញទៅមកនោះទេ។

## តើ របាយការណ៍ SPREE មានអ្វីសម្រាប់សិស្សដែលត្រូវរៀនភាសាអង់គ្លេស ឬសិស្សដែលទទួលសេវាអប់រំពិសេស?

ដោយឡែកសម្រាប់ក្រុមសិស្ស រួមទាំងសិស្សដែលត្រូវរៀនភាសាអង់គ្លេស និងសិស្សដែលទទួលសេវាអប់រំពិសេស។ សម្រាប់ការវាស់វែងទាំងនេះ សាលាមានគោលដៅដូចគ្នាសម្រាប់ក្រុមសិស្សទាំងអស់–ពោលគឺលទ្ធផលរបស់សាលាត្រូវបានរំពឹងទុកថានឹងឈានដល់កម្រិតដូចគ្នាសម្រាប់ក្រុមសិស្សផ្សេងៗគ្នាដែលសាលាបម្រើ។

ក្នុងរយៈពេលជាច្រើនឆ្នាំ – របាយការណ៍ SPREE ក៏នឹងរួមបញ្ចូលការវាយតម្លៃរួមនៃលទ្ធផលរបស់សាលាសម្រាប់ក្រុមសិស្សនីមួយៗដែលសាលាបានបម្រើផងដែរ។ ការវាយតម្លៃនេះផ្តល់នូវការយល់ដឹងថាតើសាលាកំពុងបំពេញតាមគោលដៅរបស់ខ្លួន និងកំពុងធ្វើបានប្រសើរជាងមុនសម្រាប់ក្រុមសិស្សទាំងអស់ដែលសាលាបម្រើដែរឬអត់។

## តើអត្រាបញ្ចប់ការសិក្សាមានអ្វីសម្រាប់សិស្សដែលទទួលសេវាអប់រំពិសេសរហូតដល់អាយុ ២១ ឆ្នាំ?

អត្រាបញ្ចប់ការសិក្សានៃក្រុម ៤ ឆ្នាំ រួមមាន សិស្សទាំងអស់ដែលបានចូលរៀននៅវិទ្យាល័យក្នុងឆ្នាំនៃក្រុមនេះ (សម្រាប់របាយការណ៍ឆ្នាំ ២០២១-២០២២ សិស្សដែលចូលរៀនថ្នាក់ទី ៩ ដំបូង ក្នុងឆ្នាំសិក្សា ២០១៨-២០១៩) សិស្សដែលទទួលសេវាអប់រំពិសេសរហូតដល់អាយុ ២១ ឆ្នាំ ត្រូវបានរួមបញ្ចូលក្នុងអត្រានេះ - ស្របតាមគោលការណ៍ណែនាំរបស់សហព័ន្ធ និងរដ្ឋសម្រាប់របៀបដែលអត្រាបញ្ចប់ការសិក្សាត្រូវបានគណនា។

សិស្សដែលទទួលសេវាអប់រំពិសេស ដែលមានសិទ្ធិបន្តចុះឈ្មោះចូលរៀនរហូតដល់អាយុ ២១ ឆ្នាំ នឹងត្រូវបានរាប់បញ្ចូលជាសិស្ស «បន្ត» (នោះគឺ សិស្សដែលមិនទាន់បានបញ្ចប់ការសិក្សា ហើយនៅតែចុះឈ្មោះនៅសាលា)។

## តើ របាយការណ៍ SPREE រួមបញ្ចូលសិស្សដែលចុះឈ្មោះក្នុងកម្មវិធីអប់រំតាមជម្រើសផ្សេង ដែរឬទេ?

សិស្សដែលនៅក្នុងកម្មវិធីអប់រំតាមជម្រើសផ្សេង - កម្មវិធីសម្រាប់យុវវ័យបោះបង់សាលា សិស្សដែលមានហានិភ័យខ្ពស់ក្នុងការបោះបង់ការសិក្សា និងសិស្សដែលមានការដាក់ពិន័យដោយផ្លាស់ប្តូរសាលា ឬបណ្តេញចេញពីសាលា - មិនត្រូវបានរាប់បញ្ចូលទៅក្នុងការគណនារង្វាស់ទាំងអស់នេះទេ ហើយក៏មិនរាប់ចូលទៅក្នុងលទ្ធផលរបស់សាលានៅក្នុងតំបន់ដែរ។

លទ្ធផលនៃកម្មវិធីអប់រំតាមជម្រើសផ្សេងនីមួយៗ បង្ហាញឱ្យឃើញនៅក្នុង របាយការណ៍ស្តីពីការរីកចម្រើននៃការអប់រំតាមជម្រើសផ្សេង [Alternative Education Progress Reports (AEPR)] ដែលចេញផ្សាយជារៀងរាល់ឆ្នាំ។

## តើ របាយការណ៍ SPREE ត្រូវបានឱ្យពិន្ទុដូចម្តេច?

សម្រាប់រង្វាស់ដែលត្រូវបានឱ្យពិន្ទុនីមួយៗនៅលើ របាយការណ៍ SPREE សាលានឹងទទួលការវាយតម្លៃមួយ ក្នុងចំណោមនៃការវាយតម្លៃ បួន៖

- **ធ្វើបានតាមតម្រូវការ និងប្រសើរជាងមុន (ពណ៌ខៀវ)** – ធ្វើបានតាមគោលដៅនៃលទ្ធផលក្នុងឆ្នាំបច្ចុប្បន្ន និងប្រសើរជាងលទ្ធផលពីឆ្នាំមុន
  - សាលាដែលធ្វើបានតាមគោលដៅឆ្នាំ ២០២៥-២០២៦ សម្រាប់មាត្រដ្ឋាន ទទួលបានស្លាកថា «ធ្វើបានតាមគោលដៅឆ្នាំ ២០២៦» ដែលបង្ហាញជាពណ៌ខៀវ មិនថាធ្វើបានប្រសើរជាងឆ្នាំមុន ឬយ៉ាងណានោះទេ។
  - សាលាដែលគ្មានព័ត៌មានពីឆ្នាំមុន ប៉ុន្តែធ្វើបានតាមគោលដៅរបស់ឆ្នាំបច្ចុប្បន្ន ទទួលស្លាកថា «ធ្វើបានតាមតម្រូវការ» ដែលបង្ហាញជាពណ៌ខៀវ។
- **ធ្វើបានតាមតម្រូវការ ប៉ុន្តែមិនប្រសើរជាងមុន (ពណ៌បៃតង)** – ធ្វើបានតាមគោលដៅនៃលទ្ធផលក្នុងឆ្នាំបច្ចុប្បន្ន ប៉ុន្តែមិនប្រសើរជាងលទ្ធផលពីឆ្នាំមុន
- **ធ្វើមិនបានតាមតម្រូវការ ប៉ុន្តែធ្វើបានប្រសើរជាងមុន (ពណ៌លឿង)** – ធ្វើមិនបានតាមគោលដៅនៃលទ្ធផលរបស់ឆ្នាំបច្ចុប្បន្ននៅឡើយ ប៉ុន្តែធ្វើបានប្រសើរជាងលទ្ធផលកាលពីឆ្នាំមុន
  - សាលាដែលគ្មានព័ត៌មានពីឆ្នាំមុន ហើយធ្វើមិនបានតាមគោលដៅនៃឆ្នាំបច្ចុប្បន្ន ទទួលស្លាកថា «ធ្វើមិនបានតាមតម្រូវការ» ដែលបង្ហាញជាពណ៌លឿង។

- **ធ្វើមិនបានតាមតម្រូវការ និងធ្វើមិនបានប្រសើរជាងមុន (ពណ៌ក្រហម)** – ធ្វើមិនបានតាមគោលដៅនៃលទ្ធផលក្នុងឆ្នាំបច្ចុប្បន្ន ហើយធ្វើមិនបានប្រសើរជាងលទ្ធផលកាលពីឆ្នាំមុន

គោលដៅប្រចាំឆ្នាំគឺស្របគ្នាទូទាំងបណ្ដាសាលា ហើយត្រូវបានកំណត់ជារៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ ២០២៥-២០២៦។ ព័ត៌មានលម្អិតអំពីគោលដៅនីមួយៗនៃគោលដៅទាំងនេះមាននៅក្នុង សៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់របាយការណ៍ SPREE និងនៅលើ គេហទំព័រសម្រាប់របាយការណ៍ SPREE របស់ក្រសួងអប់រំ (District's SPREE webpage)។

## តើការបង្ហាញថាធ្វើបានប្រសើរជាងមុនមានន័យដូចម្ដេចសម្រាប់រង្វាស់នេះ?

ដើម្បីចាត់ទុកថា «ធ្វើបានប្រសើរជាងមុន» សាលាត្រូវធ្វើឱ្យបានតាមលក្ខណៈវិនិច្ឆ័យណាមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមនេះ៖

- ធ្វើបានប្រសើរជាងមុនដោយមានពិន្ទុភាគរយយ៉ាងហោចណាស់ ២ ភាគរយ សម្រាប់មាត្រដ្ឋានដែលផ្អែកលើភាគរយ (ដូចជា PSSA ឬអត្រាបញ្ចប់ការសិក្សា) ដែលមានមូលដ្ឋានរង្វាស់ពី 0.0% ទៅ 100.0%
- ធ្វើបានប្រសើរជាងមុន ដោយមានពិន្ទុយ៉ាងហោចណាស់ 0.1 សម្រាប់មាត្រដ្ឋានស្ទង់មតិដែលមានមូលដ្ឋានរង្វាស់ពី 0.0 ទៅ 10.0
- ធ្វើបានប្រសើរជាងមុន ដោយមានយ៉ាងហោចណាស់ ១ ប្រភេទ សម្រាប់មាត្រដ្ឋាន PVAAS AGI។ ត្រូវបានពន្យល់នៅពេលក្រោយ នៅក្នុងសំណួរដែលគេឧស្សាហ៍សួរទាំងនេះ (FAQs) ប្រភេទ PVAAS AGI គឺ -2.00 និងទាបជាង, -1.99 ដល់ -1.00, -1.00 ដល់ +1.00, +1.00 ដល់ +1.99, និង +2.00 ឡើងទៅ។

## ហេតុអ្វីបានជាគ្មានទិន្នន័យថាតើសាលាធ្វើបានប្រសើរជាងមុនឬអត់?

វាអាចទៅរួចដែលទិន្នន័យថាតើសាលាធ្វើបានប្រសើរជាងមុនឬអត់អាចនឹងមិនមានសម្រាប់មូលហេតុមួយចំនួន រួមទាំង៖

- រង្វាស់ដែលមិនអាចគណនាបានសម្រាប់ឆ្នាំមុនដោយសារកាលៈទេសៈអ្វីមួយ ដូចជា ការប្រែប្រួលទាក់ទងនឹងជំងឺ COVID ឬការបិទសាលាជាដើម។
- សិស្សមួយចំនួនតូចមានសិទ្ធិទទួលមាត្រដ្ឋានក្នុងឆ្នាំមុន (ឧ. សាលាដែលមានសិស្សត្រូវរៀនភាសាអង់គ្លេសចំនួន ១៥ នាក់ ក្នុងឆ្នាំមុន នឹងមិនទទួលបានពិន្ទុសម្រាប់ ACCESS Growth ឬសម្រាប់មាត្រដ្ឋានក្រុមសិស្សដែលត្រូវរៀនភាសាអង់គ្លេសណាមួយបានទេ)។
- សាលាដែលមិនបានបើក ឬមិនមានសិទ្ធិទទួលបានរបាយការណ៍ SPREE កាលពីឆ្នាំមុន
- សាលាមិនបានផ្ដល់កម្មវិធីជាក់លាក់ ឬវគ្គសិក្សាដែលចាំបាច់សម្រាប់មាត្រដ្ឋាន (ឧ. ការអប់រំផ្នែកអាជីព និងបច្ចេកទេស)។
- សាលាឆាធ័រដែលបានជ្រើសរើសចូលរួមក្នុងរបាយការណ៍ SPREE ជាលើកដំបូង

*សម្រាប់របាយការណ៍ SPREE ឆ្នាំ ២០២១-២០២២ - យើងមិនប្រៀបធៀបលទ្ធផលដែលធ្វើបានទៅនឹងតម្លៃដែលបានបង្ហាញនៅក្នុង SPREE Lite ឆ្នាំ ២០២០-២០២១ ទេ ដូច្នេះការរីកចម្រើនមិនត្រូវបាន*

*រាប់បញ្ចូលសម្រាប់មាត្រដ្ឋានណាមួយនៅលើរបាយការណ៍ SPREE ២០២១-២០២២ ទេ។*

## តើសាលាត្រូវបានឱ្យពិន្ទុដូចម្តេចនៅពេលដែលគ្មានទិន្នន័យពីឆ្នាំមុន?

ប្រសិនបើគ្មានទិន្នន័យពីឆ្នាំមុនសម្រាប់រង្វាស់ទេ សាលាទទួលការវាយតម្លៃថា «ធ្វើបានតាមតម្រូវការ» ឬ «ធ្វើមិនបានតាមតម្រូវការ» យោងទៅលើថាតើសាលា ឬក្រុមសិស្សធ្វើបានតាមតម្រូវការទៅតាមគោលដៅដែលត្រូវបំពេញក្នុងឆ្នាំបច្ចុប្បន្នសម្រាប់រង្វាស់ដែរឬអត់។

ទោះបីជាមិនពាក់ព័ន្ធសម្រាប់របាយការណ៍ SPREE ឆ្នាំ ២០២១-២២ ក៏ដោយ សម្រាប់ឆ្នាំរាយការណ៍នៅពេលដែលមានទិន្នន័យនៃការរីកចម្រើន ប៉ុន្តែប្រ

ហែលជាមិនមែនសម្រាប់រង្វាស់ទាំងអស់ កម្រិតទាំងអស់ផ្អែកលើ *ចំនួនរង្វាស់ដែលសាលាមានទិន្នន័យនៃការរីកចម្រើន។* ដូច្នេះ សាលាដែលគ្មានទិន្នន័យពីឆ្នាំមុនសម្រាប់រង្វាស់អ្វីមួយ នឹងប្រើរង្វាស់ផ្សេងគ្នា នៅពេលពិនិត្យមើលភាគរយដែលសាលាមានការរីកចម្រើន។

## តើ «កម្រិត» របស់សាលាខ្ញុំបង្ហាញអ្វីខ្លះ?

កម្រិតរបស់សាលាឆ្លុះបញ្ចាំងពីភាគរយនៃមាត្រដ្ឋានដែលសាលាធ្វើបានតាមតម្រូវការ តាមគោលដៅប្រចាំឆ្នាំ និងភាគរយនៃមាត្រដ្ឋានដែលសាលាធ្វើបានប្រសើរជាងមុន (ដោយមិនគិតពី ការធ្វើបាន ឬមិនបាន តាមគោលដៅរបស់ខ្លួន)។ ផ្អែកលើតម្លៃទាំងនេះ សាលាត្រូវបានដាក់ស្លាកតាមកម្រិតមួយក្នុងចំណោមប្រាំមួយកម្រិត៖

- **កម្រិត 1** – ធ្វើបានតាមតម្រូវការយ៉ាងហោចណាស់ 67% នៃគោលដៅ ហើយនៅពេលមានទិន្នន័យនៃការរីកចម្រើន ការធ្វើបានប្រសើរជាងមុនយ៉ាងហោចណាស់ 50% នៃគោលដៅ
- **កម្រិត 2** – ធ្វើបានតាមតម្រូវការយ៉ាងហោចណាស់ 67% នៃគោលដៅ ប៉ុន្តែធ្វើបានប្រសើរជាងមុនតិចជាង 50% នៃគោលដៅ (កម្រិតនេះមិនត្រូវបានប្រើទេ នៅពេលណាគ្មានទិន្នន័យនៃការរីកចម្រើន)
- **កម្រិត 3** – ធ្វើបានតាមតម្រូវការ 34-66% នៃគោលដៅ ហើយនៅពេលមានទិន្នន័យនៃការរីកចម្រើន ការរីកចម្រើនយ៉ាងហោចណាស់ 50% នៃគោលដៅ
- **កម្រិត 4** – ធ្វើបានតាមតម្រូវការ 34-66% នៃគោលដៅ ប៉ុន្តែការរីកចម្រើនតិចជាង 50% នៃគោលដៅ (កម្រិតនេះមិនត្រូវបានប្រើទេ នៅពេលណាគ្មានទិន្នន័យនៃការរីកចម្រើន)
- **កម្រិត 5** – ធ្វើបានតាមតម្រូវការ 0-33% នៃគោលដៅ នៅពេលមានទិន្នន័យនៃការរីកចម្រើន ការរីកចម្រើនយ៉ាងហោចណាស់ 50% នៃគោលដៅ
- **កម្រិត 6** – ធ្វើបានតាមតម្រូវការ 0-33% នៃគោលដៅ ប៉ុន្តែការរីកចម្រើនតិចជាង 50% នៃគោលដៅ (កម្រិតនេះមិនត្រូវបានប្រើទេ នៅពេលណាគ្មានទិន្នន័យនៃការរីកចម្រើន)

*សម្រាប់របាយការណ៍ SPREE ឆ្នាំ ២០២១-២០២២ - មានតែកម្រិត 1, 3, និង 5 ប៉ុណ្ណោះដែលត្រូវបានគណនា ដោយសារតែការមិនរាប់បញ្ចូលទិន្នន័យពីឆ្នាំមុន។*

## តើគោលដៅសម្រាប់រង្វាស់នីមួយៗត្រូវបានកំណត់

## យ៉ាងដូចម្តេច?

សម្រាប់រង្វាស់ដែលផ្អែកលើ Goals and Guardrails (ឧ. អត្រាស្ទាត់ជំនាញ PSSA) គោលដៅនៃមាត្រដ្ឋាន គឺដូចគ្នាទៅនឹងមាត្រដ្ឋានដែលត្រូវបានពិចារណាជារៀងរាល់ឆ្នាំដោយក្រុមប្រឹក្សាអប់រំ។

សម្រាប់រង្វាស់ដែលស្របតាមគោលដៅរបស់រដ្ឋ (ឧ. អត្រាបញ្ចប់ការសិក្សា) គោលដៅប្រចាំឆ្នាំរបស់រដ្ឋ – ឬគោលដៅប្រចាំឆ្នាំដែលបានបង្កើតឡើងដោយក្រសួងអប់រំ ដែលនាំឱ្យក្រសួងអប់រំអាចបំពេញតាមគោលដៅទៅកាន់គោលដៅឆ្នាំ ២០៣០ របស់រដ្ឋ – ត្រូវបានប្រើប្រាស់។

## តើមានព័ត៌មានបន្ថែមអំពីរបៀបដែលមាត្រដ្ឋាននីមួយៗត្រូវបានគណនាដែរឬទេ?

បន្ថែមពីលើនិយមន័យនៃមាត្រដ្ឋានដែលបានផ្តល់នៅក្នុងសៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់ របាយការណ៍ SPREE ច្បាប់អាជីវកម្មសាធារណៈសម្រាប់ការគណនានីមួយៗមាននៅលើ គេហទំព័ររបាយការណ៍ SPREE របស់ក្រសួងអប់រំ (District's SPREE webpage)។ ច្បាប់ទាំងនេះមានគោលបំណងផ្តល់នូវការពិពណ៌នាទូទៅកម្រិតខ្ពស់នូវអ្វីៗដែលចូលទៅក្នុងមាត្រដ្ឋាននីមួយៗ រួមទាំងប្រភពនៃទិន្នន័យដែលសិស្សត្រូវបានបញ្ចូលក្នុងការគណនា ហើយថាតើសាលាណាមានសិទ្ធិទទួលមាត្រដ្ឋាននេះ។

## ហេតុអ្វីបានជាមាត្រដ្ឋានពិន្ទុនៅលើរបាយការណ៍ SPREE អាចនឹងខុសគ្នាពីព័ត៌មានស្រដៀងគ្នាដែលបានចែករំលែកនៅទីដទៃ?

មានមូលហេតុជាច្រើនដែលរបាយការណ៍ SPREE អាចនឹងបង្ហាញព័ត៌មានខុសគ្នាពេលប្រៀបធៀបទៅនឹងប្រភពផ្សេងទៀត រួមមាន៖

- **គំរូ** – ជួនកាលរបាយការណ៍ SPREE ឆ្លុះបញ្ចាំងគំរូសិស្សខុសគ្នាពីប្រភពទិន្នន័យផ្សេងទៀត ដូចជា សន្ទស្សន៍ត្រៀមខ្លួនសម្រាប់អនាគតរបស់ក្រសួងអប់រំរដ្ឋ ផិនស៊ីលវេនញ៉ា [Pennsylvania Department of Education's Future Ready Index (FRI)] ឬ ប្រព័ន្ធព័ត៌មានផ្ទៃក្នុងរបស់សាលា។ ឧទាហរណ៍ មាត្រដ្ឋាន PSSA នៅលើរបាយការណ៍ SPREE ឆ្លុះបញ្ចាំងពីការបំពេញបានរបស់សិស្សដែលបានចុះឈ្មោះចូលរៀនសម្រាប់រយៈពេលពេញឆ្នាំសិក្សា។ ទោះជាយ៉ាងណាក៏ដោយ សាលានីមួយៗអាចឃើញលទ្ធផលសម្រាប់សិស្សទាំងអស់ដែលត្រូវបានវាយតម្លៃនៅអគារសិក្សា ដោយមិនគិតថាតើពួកគេត្រូវបានចុះឈ្មោះចូលរៀននៅសាលាយូរប៉ុនណានោះទេ។
- **ការកំណត់ពេលវេលា** – ប្រភពផ្សេងទៀតអាចនឹងមើលទៅរយៈពេលខុសពីរបាយការណ៍ SPREE។ ឧទាហរណ៍ អត្រាទទួលបានការចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យក្នុងរដូវស្លឹកឈើជ្រុះដំបូងដែលបានបង្ហាញនៅលើរបាយការណ៍ SPREE ឆ្នាំ ២០២១-២២ ឆ្លុះបញ្ចាំងការចុះឈ្មោះចូលរៀននៅរដូវស្លឹកឈើជ្រុះ ឆ្នាំ ២០២២ របស់សិស្សដែលបានបញ្ចប់ការសិក្សាឆ្នាំ ២០២១-២០២២។ ទោះជាយ៉ាងណាក៏ដោយ អត្រាទទួលការចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យដែលបានបង្ហាញនៅលើ FRI «យឺតយ៉ាវ» មួយឆ្នាំ –ពេលគឺអត្រាទទួលការចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យ នៅលើ FRI សម្រាប់ឆ្នាំសិក្សា ២០២១-

២០២២ ឆ្លុះបញ្ចាំងពីការចុះឈ្មោះចូលរៀនរបស់សិស្សដែលបានបញ្ចប់ការសិក្សានៅឆ្នាំ ២០២០-២០២១។

- **និយមន័យ** – មាត្រដ្ឋាននៅលើរបាយការណ៍ SPREE អាចនឹងត្រូវបានគណនាខុសគ្នាបន្តិចពីមាត្រដ្ឋានស្រដៀងគ្នាដែលមាននៅទីដទៃ។ ឧទាហរណ៍ មាត្រដ្ឋានវត្តមានអវត្តមាននៅលើរបាយការណ៍ SPREE ឆ្លុះបញ្ចាំងពីភាគរយរបស់សិស្សដែលវត្តមាននូវភាគរយនៃថ្ងៃមួយចំនួន (ឧទាហរណ៍ 95% ឬ ច្រើនជាងនេះ នៃថ្ងៃរៀន) ខណៈដែលការគណនាវត្តមានអវត្តមានដែលបានចុះផ្សាយដោយទីភ្នាក់ងារដៃគូអាចនឹងឆ្លុះបញ្ចាំងពីការគណនាមួយផ្សេងទៀត ដូចជា មធ្យមភាគប្រចាំថ្ងៃនៃវត្តមានអវត្តមាន។

### ហេតុអ្វីបានជាសាលាខ្លះមានរបាយការណ៍ SPREEs ពីរ?

ដោយសារគោលដៅជាក់លាក់របស់ក្រុមប្រឹក្សាអប់រំចំពោះកម្រិតថ្នាក់រៀងៗខ្លួន របាយការណ៍ SPREE វាយតម្លៃលទ្ធផលរបស់សិស្សសម្រាប់លំដាប់ថ្នាក់ណាមួយ។ ដូច្នេះ សាលាដែលបង្រៀនសិស្សអនុវិទ្យាល័យ និងវិទ្យាល័យ ទទួលបានរបាយការណ៍ដាច់ដោយឡែកពីគ្នាសម្រាប់លំដាប់ថ្នាក់នីមួយៗ ដើម្បីឱ្យលទ្ធផលរបស់សិស្សអាចវាយតម្លៃដាច់ដោយឡែកពីគ្នា។ ឧទាហរណ៍ សាលាដែលបង្រៀនសិស្សថ្នាក់ទី ៥ ដល់ ទី ១២ នឹងទទួលរបាយការណ៍អនុវិទ្យាល័យ (សម្រាប់ថ្នាក់ទី ៥ ដល់ ទី ៨) និងរបាយការណ៍វិទ្យាល័យ (សម្រាប់ថ្នាក់ទី ៩ ដល់ ទី ១២)។

### ហេតុអ្វីបានជាសាលាខ្លះគ្មានរបាយការណ៍ SPREE?

សាលាដែលអប់រំសិស្សតាមជម្រើសផ្សេង សាលាដែលបង្រៀនសិស្សកម្រិតថ្នាក់តែមួយនៅក្នុងថ្នាក់ដែលអាចបង្កើនការសិក្សារបស់សិស្ស និងសាលាឆាធ័រដែលស្ថិតនៅក្នុងស្ថានភាពមិនបន្តទៅទៀត មិនទទួលរបាយការណ៍ SPREE ទេ។ ឧទាហរណ៍ សាលាឆាធ័រ YouthBuild Philadelphia ធ្វើបានតាមតម្រូវការទាំងអស់ដើម្បីទទួលបានរបាយការណ៍ SPREE ប៉ុន្តែមិនមានសិទ្ធិដោយសារកម្រិតថ្នាក់មានកំណត់ (តែថ្នាក់ទី ១២ ប៉ុណ្ណោះ) និងគំរូសាលាប្លែកពីគេ។ លើសពីនេះទៀត មិនមែនសាលាឆាធ័រទាំងអស់ជ្រើសរើសចូលរួមក្នុងរបាយការណ៍ SPREE នោះទេ។

### ហេតុអ្វីបានជាគ្មានទិន្នន័យឆ្នាំ ២០២១-២២ សម្រាប់សាលាឆាធ័រ?

ការបញ្ចេញរបាយការណ៍ SPREE ឆ្នាំ ២០២១-២០២២ ដំបូង មិនរួមបញ្ចូលរបាយការណ៍សម្រាប់សាលាឆាធ័រវិញទេ ដោយសារទិន្នន័យពី ក្រសួងអប់រំរដ្ឋផិនស៊ីលវេនញ៉ា (PDE) ត្រូវបានពន្យារពេល។ នៅពេលដែលទិន្នន័យសាលាឆាធ័របញ្ចេញដោយ PDE ទៅឱ្យក្រសួងអប់រំ របាយការណ៍សាលាឆាធ័រនឹងត្រូវបានបង្កើតឡើង និងចេញផ្សាយនៅលើគេហទំព័ររបស់ក្រសួងអប់រំ។

### តើសាលាឆាធ័រណាខ្លះដែលចូលរួម?

ការចេញផ្សាយនៅឆ្នាំនេះរួមមានប្រហែល 99% នៃសាលាឆាធ័រដែលមានសិទ្ធិទាំងអស់ ដែលដំណើរការនៅឆ្នាំ ២០២១-២០២២ – ឬទាំងអស់ លើកលែងតែសាលាឆាធ័រដែលមានសិទ្ធិមួយ។ អ្នកចូលរួមជាមួយសាលាឆាធ័រឱ្យតម្លៃលើការប្រៀបធៀបនូវលក្ខណៈដូចគ្នានៃការរីកចម្រើនទូទាំងសាលានៅក្នុងទីក្រុងទាំង

អស់ និងឱ្យតម្លៃលើមតិដ៏ទូលំទូលាយនៃការបំពេញ និងការរីកចម្រើនរបស់សាលាដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ SPREE។

### តើរបាយការណ៍ SPREE ឆ្លុះបញ្ចាំងការប្ដេជ្ញារបស់ក្រសួងអប់រំចំពោះសមធម៌យ៉ាងដូចម្ដេច?

របាយការណ៍ SPREE ផ្ដោតទៅលើសមធម៌តាមវិធីជាច្រើន៖

- **លទ្ធផលរបស់សាលានៅកម្រិតមាត្រដ្ឋានសម្រាប់ក្រុមសិស្សនីមួយៗដែលបានបម្រើ** – របាយការណ៍ SPREE រួមបញ្ចូលព័ត៌មានស្ដីពីលទ្ធផលដែលសិស្សរៀនបាន និងការធ្វើបានប្រសើរជាងមុន របស់សាលានៅក្នុងរង្វាស់នីមួយៗដែលត្រូវបានបែងចែកដោយក្រុមសិស្ស – ឧទាហរណ៍ តើសាលាធ្វើបានដូចម្ដេចចំពោះការវាយតម្លៃការអានរបស់រដ្ឋ សម្រាប់សិស្សដែលទទួលសេវាអប់រំពិសេស។
- **រង្វាស់ថ្មីអំពីលទ្ធភាពដែលអាចទទួលបាន និងឱកាស** – មាត្រដ្ឋានជាច្រើននៅលើរបាយការណ៍ SPREE ពិនិត្យមើលជាពិសេសថាតើក្រុមសិស្សផ្សេងៗគ្នាដែលនៅក្នុងសាលាមានឱកាសស្រដៀងគ្នាដែរឬអត់ – ឧទាហរណ៍ លទ្ធភាពទទួលបានវគ្គសិក្សាកម្រិតខ្ពស់ស្រដៀងគ្នា។
- **ការវាយតម្លៃកម្រិតសាលាសម្រាប់ក្រុមសិស្ស** – ក្រៅពីការផ្ដល់កម្រិតថ្នាក់ទូទាំងសាលាដោយផ្អែកលើលទ្ធផលដែលសិស្សរៀនបាន និងការធ្វើបានប្រសើរជាងមុន របាយការណ៍ SPREE កំណត់កម្រិតថ្នាក់ឱ្យដាច់ដោយឡែកដោយផ្អែកលើការធ្វើបាន និងការធ្វើបានប្រសើរជាងមុន សម្រាប់ក្រុមសិស្សនីមួយៗ។

រួមគ្នា សមាសភាគនៃរបាយការណ៍ SPREE ទាំងនេះជួយបង្ហាញថាតើសាលាកំពុងបម្រើសិស្សទាំងអស់របស់ខ្លួនដោយជោគជ័យឬអត់។

### តើមាត្រដ្ឋានដែលផ្អែកលើការស្ទង់មតិត្រូវបានឲ្យពិន្ទុដូចម្ដេច?

របាយការណ៍ SPREE មានមាត្រដ្ឋានស្ទង់មតិដែលឱ្យពិន្ទុចំនួន បី ដែលប្រើទិន្នន័យពីការស្ទង់មតិ មាតាបិតា និងអាណាព្យាបាល សិស្ស និងគ្រូ ទូទាំងក្រសួងអប់រំក្នុងឆ្នាំ ២០២១-២០២២៖

1. ពិន្ទុផ្នែកបង្ហាត់បង្រៀន (រួមបញ្ចូលចម្លើយពី ឪពុកម្ដាយ/អាណាព្យាបាល សិស្ស និងគ្រូ)
2. ពិន្ទុផ្នែកសន្តិសុខ រួមបញ្ចូលចម្លើយពី ឪពុកម្ដាយ/អាណាព្យាបាល សិស្ស និងគ្រូ
3. ពិន្ទុផ្នែកទំនាក់ទំនងជាមួយសាលា រួមបញ្ចូលចម្លើយពី ឪពុកម្ដាយ/អាណាព្យាបាល

សម្រាប់មាត្រដ្ឋានស្ទង់មតិ សាលាមិនទទួលបានពិន្ទុទេ ប្រសិនបើសាលាមិនបំពេញបានតាមកម្រិតអប្បបរមានៃការចូលរួម។

សម្រាប់ពិន្ទុផ្នែកបង្ហាត់បង្រៀន និងសន្តិសុខ សាលាត្រូវតែបំពេញបានទៅតាមកម្រិតនៃការចូលរួម យ៉ាងហោចណាស់ ពីក្រុមអ្នកឆ្លើយតបដែលពាក់ព័ន្ធ ពីរក្រុមក្នុងចំណោម បីក្រុម (សិស្ស ឪពុកម្ដាយ/អាណាព្យាបាល និង គ្រូ)។ ដើម្បីឱ្យត្រូវតាមកម្រិតនៃការចូលរួមត្រូវតែមានអ្នកឆ្លើយសំណួរយ៉ាងតិច ៥ នាក់ នៅក្នុងក្រុមឆ្លើយតប និងតម្រូវការអត្រានៃការចូលរួមអប្បបរមាត្រូវតែមានតាមចំនួនដូចតទៅ៖

- អប្បបរមា 25% សម្រាប់គ្រូបង្រៀន និងសិស្ស

(នៅថ្នាក់ទី ៣ ដល់ ទី ១២) *និង*

- អប្បបរមា 10% សម្រាប់ក្រុមគ្រួសារ

ឧទាហរណ៍ កម្រិតនៃការចូលរួមសម្រាប់សាលាដែលមានសិស្ស ១០០ នាក់ នៅថ្នាក់ទី ៣ ដល់ ទី ១២ គឺ ២៥ នាក់ ខណៈដែលកម្រិតនៃការចូលរួមសម្រាប់សាលាដែលបមានសិស្ស ៦០០ នាក់ នៅក្នុងថ្នាក់ទី ៣ ដល់ ទី ១២ គឺ ១៥០ នាក់។

សម្រាប់ពិន្ទុផ្នែកទំនាក់ទំនងសាលា មានក្រុមឆ្លើយតបដែលពាក់ព័ន្ធតែមួយប៉ុណ្ណោះ៖ ឪពុកម្តាយ/អាណាព្យាបាល។ សាលាត្រូវតែមានការឆ្លើយតបយ៉ាងតិច ៥ ពីឪពុកម្តាយ/អាណាព្យាបាល ដែលតំណាងឱ្យយ៉ាងហោចណាស់ 10% នៃគ្រួសារ ដើម្បីឱ្យត្រូវតាមកម្រិតដែលបានកំណត់។

ប្រសិនបើសាលាធ្វើបានតាមកម្រិតនៃការចូលរួម សាលាទទួលបាន ពិន្ទុ “overall topic score” នៅលើរង្វាស់ 0.0-10.0។ ការធ្វើបានតាមកម្រិតអប្បបរមានៃការចូលរួម មិនធានាថាសាលាទទួលបានការវាយតម្លៃថា «ធ្វើបានតាមតម្រូវការ» សម្រាប់មាត្រដ្ឋានទាំងនេះទេ។

ព័ត៌មានបន្ថែមអំពីកម្រិត និងការឱ្យពិន្ទុ មាននៅក្នុង របាយការណ៍របស់អ្នកស្រាវជ្រាវ (technical report)។

## តើសំណួរអ្វីខ្លះត្រូវរួមបញ្ចូលក្នុងមាត្រដ្ឋានស្ទង់មតិ?

ការិយាល័យស្រាវជ្រាវ និងវាយតម្លៃ [Office of Research and Evaluation (ORE)] បង្កើតមាត្រដ្ឋានស្ទង់មតិ និងចាត់ចែង ការស្ទង់មតិទូទាំងក្រសួង (District-Wide Survey)។ សំណួរជាក់លាក់ដែលរួមបញ្ចូលក្នុងមាត្រដ្ឋានអាចនឹងផ្លាស់ប្តូរតាមពេលវេលា ប៉ុន្តែច្បាប់ចម្លងនៃការស្ទង់មតិប្រចាំឆ្នាំនីមួយៗមាននៅលើ គេហទំព័រ (website) របស់ ORE។ ព័ត៌មានបន្ថែមអំពីការស្ទង់មតិ រួមទាំងចម្លើយទៅនឹងសំណួរនៃការស្ទង់មតិនីមួយៗ អាចឃើញមាននៅក្នុង អនឡាញ (online)។

## តើ តម្លៃ PVAAS AGI វាស់អ្វីខ្លះ ហើយមាត្រដ្ឋានទាំងនោះត្រូវឱ្យពិន្ទុដូចម្តេច?

មាត្រដ្ឋាន PVAAS AGI វាស់ការរីកចម្រើនរបស់សិស្ស ពីមួយឆ្នាំទៅមួយឆ្នាំ ដោយមិនគិតថាតើពួកគេបានចូលទៅក្នុងឆ្នាំសិក្សាតាមកម្រិតថ្នាក់ ក្រោមកម្រិតថ្នាក់ ឬខ្ពស់ជាងកម្រិតថ្នាក់ នោះទេ។ ការរីកចម្រើនរបស់សិស្សត្រូវបានគណនាសម្រាប់ថ្នាក់ទី ៤ ដល់ ទី ៨ និង វិទ្យាល័យ ដោយប្រើលទ្ធផលពីឆ្នាំមុន និងឆ្នាំបច្ចុប្បន្នរបស់ពួកគេ នៅលើការវាយតម្លៃទូទាំងរដ្ឋ (PSSAs និង Keystones)។

ក្រសួងអប់រំរដ្ឋ ផិនស៊ីលវេនញ៉ា (PDE) ចាត់តម្លៃ AGI តាមផ្នែកដូចតទៅ៖

- -2.00 ចុះក្រោម (បង្ហាញជា ពណ៌ក្រហម នៅក្នុងការរាយការណ៍ PVAAS)៖ ភស្តុតាងសំខាន់ដែលថាសិស្សធ្វើមិនបានតាមស្តង់ដារសម្រាប់ការរីកចម្រើនផ្នែកសិក្សារបស់រដ្ឋ PA
- -1.00 ដល់ -1.99 (បង្ហាញជា ពណ៌លឿង នៅក្នុងការរាយការណ៍ PVAAS)៖ ភស្តុតាងកម្រិតមធ្យមដែលថាសិស្សធ្វើមិនបានតាមស្តង់ដារសម្រាប់ការរីកចម្រើនផ្នែកសិក្សារបស់រដ្ឋ PA
- -1.00 ដល់ +1.00 (បង្ហាញជា ពណ៌បៃតង នៅក្នុងការរាយការណ៍ PVAAS)៖ ភស្តុតាងដែលថាសិស្សធ្វើបានតាមស្តង់ដារសម្រាប់ការរីកចម្រើនផ្នែកសិក្សារបស់រដ្ឋ PA
- +1.00 ដល់ +1.99 (បង្ហាញជា ពណ៌ខៀវ នៅ

ក្នុងការរាយការណ៍ PVAAS)៖ ភស្តុតាងកម្រិតមធ្យមដែលថាសិស្សធ្វើបានលើសពីស្តង់ដារសម្រាប់ការរីកចម្រើនផ្នែកសិក្សារបស់រដ្ឋ PA

- +2.00 ឡើងទៅ (បង្ហាញជា ពណ៌ខៀវចាស់ នៅក្នុងការរាយការណ៍ PVAAS)៖ ភស្តុតាងរឹងមាំដែលថាសិស្សធ្វើបានលើសពីស្តង់ដារសម្រាប់ការរីកចម្រើនផ្នែកសិក្សារបស់រដ្ឋ PA

នៅលើរបាយការណ៍ SPREE សាលាមានគោលដៅ 2.00 ឬខ្ពស់ជាងនេះ (ពណ៌ខៀវចាស់នៅក្នុងការរាយការណ៍ PVAAS) សម្រាប់ឆ្នាំនីមួយៗ។ សាលាដែលមានពិន្ទុត្រឹមកម្រិតនេះ ឬលើសពីកម្រិតនេះ ទទួលការវាយតម្លៃថា «ធ្វើបានតាមតម្រូវការ» ឬ «ធ្វើបានតាមតម្រូវការ និងធ្វើបានប្រសើរជាងមុន» អាស្រ័យលើការអនុវត្តន៍ពីឆ្នាំមុនរបស់សាលា។

សាលាដែលធ្វើបានប្រសើរជាងមុន ពី «ប្រភេទ» មួយទៅប្រភេទមួយទៀត – ឧទាហរណ៍ ពី ពណ៌លឿងទៅពណ៌បៃតង (ឧ. ពី -1.50 ដល់ 0.25) – ត្រូវបានកំណត់ថាជា «ការធ្វើធ្វើបានប្រសើរជាងមុន។» សាលាដែលនៅតែស្ថិតនៅក្នុងប្រភេទពណ៌ដដែល មិនត្រូវបានគេចាត់ទុកថាធ្វើបានប្រសើរជាងមុនទេ។

សម្រាប់របាយការណ៍ SPREE ឆ្នាំ ២០២១-២០២២ - *ដោយសារតែមាត្រដ្ឋាននៃការរីកចម្រើនពឹងផ្អែកយ៉ាងខ្លាំងលើការអនុវត្តន៍របស់សិស្សពីឆ្នាំសិក្សា ២០២០-២០២១ នៅពេលដែលសិស្សមួយចំនួនតូចបានធ្វើការវាយតម្លៃរបស់រដ្ឋ មកពីមានជំងឺរាតត្បាត COVID-19 មាត្រដ្ឋាន PVAAS AGI មិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ SPREE ឆ្នាំ ២០២១-២០២២ ទេ។ PDE ក៏បានចង្អុលបង្ហាញថាលទ្ធផលពីឆ្នាំសិក្សា ២០២០-២០២១ មិនត្រូវប្រើប្រាស់សម្រាប់គោលបំណងនៃការទទួលខុសត្រូវទេ។*